APLF

Asia Pacific Leadership Forum on HIV / AIDS and Development

# សារលិខិត

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

## ប្រធានកាកបាទក្រហមកម្ពុជា

## និងជា ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំ តំបន់ អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា

## ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ ២០១៩

## ក្រោមប្រធានបទ "ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍"

- *សម្តេច ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ក្មួយៗយុវជនជាទីស្រឡាញ់រាប់អាន !*
- *បងប្អូនរួមជាតិ ជាទីមេត្រី !*

ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ក្នុងនាមកាកបាទក្រហមកម្ពុជា ក្នុងនាម ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំមានក្តីសោមនស្សរីករាយ ចូលរួមជាមួយ រាជរដ្ឋាភិបាលកម្ពុជា ជាមួយសកម្មជនប្រយុទ្ធនឹងជំងឺអេដស៍ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ព្រមទាំងប្រជាជនកម្ពុជា និងប្រជាជននៅលើសកលលោកទាំងមូល ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៩ ដែលព្រះរាជាណាចក្រកម្ពុជា បានកំណត់ប្រធានបទ "**ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និង ជំងឺអេដស៍**"។ ប្រធានបទ ដែលបានកំណត់ឡើងនេះ មានគោលបំណងគូសបញ្ជាក់ពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងប្រកប ដោយឆន្ទៈមោះមុត ឈានទៅសម្រេចបានគោលដៅ បញ្ចប់បញ្ហាអេដស៍នៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០២៥។

ក្នុងរយៈកាល ២៨ឆ្នាំ កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជារួមជាមួយដៃគូសហប្រតិបត្តិការជាតិ-អន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន ផ្នែកសាសនា និង កាកបាទក្រហមកម្ពុជា បានខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ រហូតសម្រេចបាននូវការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ធ្វើឱ្យអត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោម ប្រជាជនទូទៅចាប់ពីអាយុ ១៥ ទៅ ៤៩ ឆ្នាំ បានធ្លាក់ចុះពី ១.៦% នៅឆ្នាំ១៩៩៨ ធ្លាក់ចុះមកនៅ ១% នៅឆ្នាំ២០០៦ និងធ្លាក់ចុះជាបន្តបន្ទាប់មកនៅ 0.៨% នៅឆ្នាំ២០១០ និង 0.៥% នៅឆ្នាំ២០១៩នេះ។ ជាមួយគ្នានេះ របាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩ នេះ បានបង្ហាញឱ្យដឹងថា កម្ពុជាអាចកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី បានពី ២,៣០០នាក់ ក្នុងឆ្នាំ២០១០ មកនៅត្រឹមចំនួនប្រមាណ ៨៨0នាក់ ក្នុងឆ្នាំ២០១៩ ចំណែកឯការផ្តល់ឱសថប្រឆាំងមេរោគអេដស៍វិញ អាចសម្រេចបាន ៩៩% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ដែលកំពុងត្រូវការឱសថប្រឆាំងមេរោគអេដស៍ និងសេវាថែទាំព្យាបាល ហើយដែលជាលទ្ធផល បានធ្វើឱ្យអត្រាមរណភាពដោយសារជំងឺអេដស៍ធ្លាក់ចុះជារៀងរាល់ឆ្នាំ។ លើសពីនេះទៅទៀត អត្រាធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះបានកើនឡើងខ្ពស់ អត្រាចម្លងពីម្តាយដែលមានផ្ទុកមេរោគអេដស៍ទៅកូន និងសន្ទស្សន៍នៃការរើសអើង មើលងាយអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍មានការថយចុះខ្លាំងគួរជាទីមោទនៈ។

– ***សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ក្មួយៗយុវជន បងប្អូនរួមជាតិជាទីស្រឡាញ់ !***

ថ្វីត្បិត ព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលធំធេង និងទទួលបានជោគជ័យជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏ស្ថានភាពជោគជ័យរបស់យើងនៅផុយស្រួយនៅឡើយ ព្រោះថាយើងអាចភ្លេចអេដស៍ តែអេដស៍ពុំភ្លេចយើងឡើយ។ បើយើងធ្វេសប្រហែសតែបន្តិចដោយប្រការណាមួយនោះ ការរីករាលដាលមេរោគអេដស៍នឹងអាចផ្ទុះឡើងវិញជាមិនខានឡើយ ជាពិសេសយើងនៅមានការព្រួយបារម្ភនៅក្នុងចំណោម *ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់និងចាក់គ្រឿងញៀន ក្រុមស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានកម្សាន្តសប្បាយមនុស្សពេញវ័យ ក្រុមយុវវ័យ ក្រុមប្រជាជនចំណាកស្រុកជាដើម*។

អាស្រ័យហេតុនេះ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ដែលកំពុងស្ថិតនៅលើផ្លូវត្រូវ ក្នុងការកសាងសង្គមមួយ ដែលគ្មានបញ្ហាអេដស៍នៅឆ្នាំ ២០២៥ ពោលគឺ ៩៥% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩៥% នៃអ្នកដែលដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង ៩៥% នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគ

អេដស៍នៅក្នុងខ្លួន ព្រមទាំងបំបាត់បានទាំងស្រុងនូវការស្អប់ខ្ពើម រើសអើង និងមាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ខ្ញុំសូមអំពាវនាវ សូម សម្តេច ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ក្មួយៗយុវជន បងប្អូនរួមជាតិ ***"រួមកម្លាំងគ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍"*** ហើយក៏សូមអំពាវនាវដល់គ្រប់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន ផ្នែកសាសនា បន្តចូលរួមគាំទ្រនិងអនុវត្តដោយម៉ឺងម៉ាត់នូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ដែលជាផែនទីចង្អុលផ្លូវតែមួយគត់សម្រាប់ការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

ជាមួយគ្នានេះ ខ្ញុំសូមផ្តល់អនុសាសន៍ដូចតទៅ ៖

១- សូមសាខាកាកបាទក្រហមកម្ពុជា យុវជន អ្នកស្ម័គ្រចិត្ត ពង្រឹង ពង្រីក សកម្មភាពផ្សព្វផ្សាយ អប់រំ លើកកម្ពស់ការយល់ដឹងពីបញ្ហាអេដស៍ឱ្យបានដល់សហគមន៍ជនបទ និងត្រូវផ្តល់ការជួយឧបត្ថម្ភគាំពារដល់អ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍។

២- ចំពោះអ្នកដែលសង្ស័យថា ខ្លួនបានប្រឈមនឹងការឆ្លងមេរោគអេដស៍ សូមប្រញាប់រួសរាន់ទៅពិនិត្យឈាមរកមេរោគអេដស៍ និងទៅទទួលសេវាថែទាំ ពីមណ្ឌលសុខភាពឱ្យបានទៀងទាត់ ព្រមទាំងជៀសវាងដាច់ខាតកុំចម្លងទៅអ្នកដទៃ និងចូលរួមសហការអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

៣- ចំពោះស្ត្រីមានផ្ទៃពោះ ត្រូវទៅពិនិត្យសុខភាពឱ្យបានទៀងទាត់ និងជាពិសេសឆាប់ធ្វើតេស្តឈាម ដើម្បីទទួលសេវាការពារការចម្លងមេរោគអេដស៍ទៅទារក និងជម្រុញលើកទឹកចិត្តដៃគូមកពិនិត្យ និងទទួលសេវាព្យាបាលទាំងអស់គ្នា។

៤- សូមបងប្អូនជនរួមជាតិទាំងអស់ ត្រូវបន្តស្វែងយល់ពីការបង្ការមេរោគអេដស៍ និងការពារខ្លួនកុំឱ្យឆ្លងមេរោគអេដស៍នេះជាដាច់ខាត ជាពិសេសក្មួយៗជាយុវជន យុវនារីត្រូវប្រុងប្រយ័ត្ន និងចងចាំថាការការពារគឺចាប់ផ្តើមពីខ្លួនអ្នកផ្ទាល់។

៥- មិនត្រូវមាក់ងាយ និងរើសអើងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ជាដាច់ខាត ហើយត្រូវបង្កើតបរិយាកាសគាំទ្រដល់ក្រុមប្រឈមខ្ពស់នៅគ្រប់ទីកន្លែង ដើម្បីទទួលបានសេវា សុខភាព សេវាគាំពារសង្គម និងការការពារផ្លូវច្បាប់។

៦- សូមអ្នកផ្ទុកមេរោគអេដស៍កុំមានការខ្មាសអៀន និងរើសអើងខ្លួនឯងហើយត្រូវប្រញាប់រួសរាន់ទៅទទួលការប្រឹក្សា និងការព្យាបាលឱ្យបានទាន់ពេលវេលា។

តាមរយៈសារលិខិតមួយនេះ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា បងប្អូនជនរួមជាតិទាំងអស់ ពិតជា យល់ច្បាស់ និងបន្តផ្សព្វផ្សាយទៅកាន់សមាជិកគ្រួសារ បងប្អូន មិត្តភក្តិ និងសហគមន៍ឱ្យបានកាន់តែទូលំទូលាយថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរជ័យ សិរីមង្គលមហាប្រសើរ ជូនចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ជនរួមជាតិទាំងអស់ ក្មួយៗយុវជន យុវនារី សូមប្រកបតែនឹងសេចក្តីសុខចម្រើន និង សម្រេចបានជោគជ័យគ្រប់ភារកិច្ច ជាពិសេសបញ្ចប់បញ្ហាអេដស៍ទាំងស្រុងនៅឆ្នាំ២០២៥។

*ថ្ងៃព្រហស្បតិ៍ ១០រោចខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៩*

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**